## នាងអេសធើរ១:៤-២:៣

**ទ្រង់ក៏បង្ហាញអស់ទាំងមហាសម្បត្តិ នៃនគរដ៏ឧត្តុង្គឧត្តមរបស់ទ្រង់ នឹងកិត្តិយសនៃអានុភាពដ៏វិសេសរបស់ទ្រង់ ឱ្យគេឃើញជាយូរថ្ងៃ គឺអស់១៨០ថ្ងៃ (នាងអេសធើរ១:៤)។**

ពិធីជប់លៀងនោះប្រព្រឹត្តទៅអស់រយៈពេល១៨០ថ្ងៃ ដែលត្រូវជា ប្រាំមួយខែ។ មហាក្សត្រមួយអង្គដែលត្រូវជាបិតារបស់ស្តេចទីដប់ប្រាំ ដែលគ្រប់គ្រងរាជ្យនៅប្រទេសបារាំង ចង់ធ្វើពិធីជប់លៀងយ៉ាងធំ អោយដូចជាស្តេចអ័ហាស្វូរុសដែរ ប៉ុន្តែពេលនោះក្រសួងហិរញ្ញវត្ថុរបស់ព្រះរាជាណាចក្របារាំង ទូលថ្វាយដល់ព្រះករុណាថា យើងមិនមានលុយគ្រប់គ្រាន់សម្រាប់ធ្វើពិធីជប់លៀងយ៉ាងយូរបែបនោះទេ។

ពិធីជប់លៀងដ៏ធំនេះសបញ្ជាក់ពីទ្រព្យសម្បត្តិមហាកច្រ និងភាពរុងរឿងនៃរាជ្យដ៏ធំមួយក្នុងលោកខាងកើត។ មូលហេតុដែលស្តេចអ័ហាស៊ូរុស ប្រមូលពួកអ្នកគ្រប់គ្រង និងស្តេច១២៧ប្រទេស មកធ្វើពិធីជប់លៀងយ៉ាងធំដល់ម្ល៉េះ ពីព្រោះស្តេចអង្គនោះចង់អោយស្តេចគ្រប់នគរ គាំទ្រចម្បាំងមួយដ៏ធំ ដែលស្តេចអង្គនេះបម្រុងនឹងវាយមកលើប្រទេសក្រេក។ បើស្តេចអ័ហាស៊ូរុសវាយឈ្នះប្រទេសក្រេក ស្តេចអង្គនេះនឹងក្លាយទៅជាអ្នកគ្រប់គ្រងពិភពលោកតែមួយអង្គគត់។ មហិច្ឆតាខាងផ្នែកនយោបាយរបស់ស្តេចអង្គនេះ ស្ទើរតែនឹងសម្រេចទិសដៅរបស់ខ្លួន។ ប៉ុន្តែ ដោយសារ

ការបរាជ័យរបស់ស្តេចអង្គនេះ បានជាអំណាចត្រូវផ្ទេរពីពិភពលោកខាងកើត ទៅអោយពិភពលោកខាងលិចមកទល់ពេលសព្វថ្ងៃនេះ។

ព្រះបាទស៊ូរុស ធ្វើពិធីជប់លៀងយ៉ាងធំ ហើយអស់រយៈពេលជាយូរថ្ងៃ ពីព្រោះតែស្តេចអង្គនេះចង់បញ្ជាក់ប្រាប់គេថា ទ្រង់មានទ្រព្យសម្បត្តិអាចចំណាយគ្រប់គ្រាន់ក្នុងការធ្វើសង្គ្រាមឈ្លានពានលោកខាងលិច។ ពិធីជប់លៀងនោះទៀតសោត ធ្វើឡើងដោយពពួកមនុស្សមិនកោតខ្លាចដល់ព្រះជាម្ចាស់។ យើងស្ទើរមិនអាចរកឃើញថា តើមានមេរៀនអ្វីទាក់ទងខាងព្រលឹងវិញ្ញាណក្នុងពិធីជប់លៀងនេះទេ។ ក្នុងពិធីជប់លៀងនេះ គ្រាន់តែបញ្ជាក់អោយយើងដឹងថា ពេលសាសន៍ដទៃគ្រប់គ្រងសកលលោកទាំងមូល គេតែងសម្រេចចិត្តធ្វើការនានា ដែលប៉ះពាល់ដល់សុខមាលភាពទូទៅ នៃសកលលោកយើង។ បើតាមយើងសង្កេតមើលព្រឹត្តិការណ៍ ដែលកើតឡើងជុំវិញពីធីជប់លៀងនេះ ហាក់ដូចជាព្រះជាម្ចាស់មិនបានជ្រាបពីដំណើរនោះទេ។ ផ្ទុយទៅវិញ បើយើងពិចារណាអោយបានជិតដល់ ព្រះជាម្ចាស់ចង់បញ្ជាក់អោយយើងដឹងថា សូម្បីពិធីជប់លៀងដ៏ធំ មានរយៈពេលយ៉ាងវែង ចំណាយអស់ថវិកាច្រើនលានដុល្លា ព្រះជាម្ចាស់កំពុងគ្រប់គ្រងលើស្ថានភាពនោះដែរ។ ទ្រង់នឹងប្រើស្ថានភាពរបស់មនុស្សលោករៀបចំឡើង អោយសម្រេចតាមព្រះហឫទ័យរបស់ទ្រង់ ដែលទ្រង់គិតសម្រេចនឹងធ្វើ។

**លុះកាលផុតថ្ងៃទាំងនោះហើយ ស្តេចទ្រង់ជប់លៀងដល់ពួកជន**

**ទាំងអស់ ទាំងធំទាំងតូច ដែលនៅស៊ូសាន ជាក្រុងហ្លួងអស់៧ថ្ងៃ នៅត្រង់ទីធ្លាក្នុងព្រះរាជឧទ្យាននៃដំណាក់ស្តេច (នាងអេសធើរ ១:៥)។**

ប្រាំពីរថ្ងៃចុងក្រោយ មុននឹងពិធីជប់លៀងត្រូវបញ្ចប់ ព្រះបាទស៊ូរុស បានធ្វើពិធីជប់លៀងយ៉ាងធំលើសពីពេលមុនៗ។ ស្តេចអង្គនេះបានហៅពួកបណ្តាជន និងអ្នកដឹកនាំជាច្រើនពាន់នាក់ អោយចូលរួមពិធីជប់លៀងដ៏ធំ ដែលប្រព្រឹត្តទៅក្នុងសួនឧទ្យាននៃដំណាក់របស់ទ្រង់។

**ដែលមានសំពត់ស បៃតង នឹងខៀវចងដោយខ្សែខ្ចូតទេសពណ៌ស្វាយ ភ្ជាប់នឹងសសរថ្មកែវដោយក្រវិលប្រាក់ ក៏មានកៅអីធ្វើពីមាស នឹងពីប្រាក់ដាក់លើកំរាលថ្មកែវពណ៌ក្រហម ស លឿង ហើយខ្មៅដែរ (នាងអេសធើរ១:៦)។**

ប្រាក់មាសគ្រឿងអលង្ការ និងវត្ថុប្រណីតទាំងឡាយសបញ្ជាក់ប្រាប់យើងអោយដឹងថា រាជ្យរបស់ព្រះបាទអ័ហាស៊ូរុស ជារាជ្យដែលមានទ្រព្យសម្បត្តិលើសពីមហាចក្រ។ សព្វថ្ងៃ ពួកបុរាណវិទ្យាបានជីករកឃើញវត្ថុជាច្រើន ដែលមានតម្លៃនៅប្រទេសពើស៊ីពីសម័យបុរាណ។ ប៉ុន្មានឆ្នាំកន្លងទៅនេះ គេបាននាំគ្នារំឭកពីខួបកំណើត

ទី២៥០០ឆ្នាំរបស់ប្រទេសនេះ។ នៅពេលនោះទូរទស្សន៍ និងសារព័តមានផ្សេងៗបាននិយាយយ៉ាងលំអិតអំពីធនធានដែលមានយ៉ាងច្រើននៅក្នុងប្រទេស។ ពិធីជប់លៀងដែលស្តេចអ័ហាស៊្វេរុសធ្វើ បានចំណាយថវិការអស់រាប់លានកោដិដុល្លា។ ការចំណាយលុយឥតប្រយោជន៍យ៉ាងដូច្នេះ ច្បាស់ជាមានអ្នករិះគន់យ៉ាងច្រើន។ យើងអាចធ្វើវិភាគបាននូវមូលហេតុដែលស្តេចស៊្វេរុសធ្វើពិធីជប់លៀងយ៉ាងធំនេះ។ ស្តេចនេះចង់បបួលស្តេច១២៧នគរទៀត អោយគាំទ្រជួយធ្វើសង្គ្រាមលោក ដើម្បីវាយដណ្តើមអំណាចពីលោកខាងលិច ពោលគឺពីប្រទេសក្រេក។ វិធីសាស្រ្តដែលព្រះបាទស៊្វេរុសប្រើ នៅមានគេប្រើពេលសព្វថ្ងៃនេះដែរ។ ប៉ុន្មានឆ្នាំកន្លងទៅ ក្រុមហ៊ុនរថយន្តសហរដ្ឋអាមេរិកបានធ្វើយុទ្ធនាការ ដើម្បីលក់ឡានថ្មីៗរបស់គេ។ ប្រធានក្រុមហ៊ុនបានអញ្ជើញអ្នកលក់ឡាន ពីគ្រប់ទីកន្លែងនៅលើសកលលោក ដើម្បីធ្វើពិធីជប់លៀងមួយយ៉ាងធំ។ ព្រះបាទស៊្វេរុស ហៅអ្នកដឹកនាំទាំង១២៧នគរ ដើម្បីធ្វើការជប់លៀង ពីព្រោះស្តេចអង្គនេះចង់ទិញទឹកចិត្តអ្នកដឹកនាំទាំងនោះ អោយគាំទ្រដល់លោក។ ប្រធានក្រុមហ៊ុនឡាននៅសហរដ្ឋអាមេរិកក៏ធ្វើយ៉ាងដូច្នេះដែរ។ បើគិតមើលទៅយើងឃើញថា មនុស្សលោកមិនទាន់ផ្លាស់ប្តូរគំនិតលោភលន់របស់ខ្លួននៅឡើយទេ។ មុននឹងគេធ្វើអ្វីមួយ គេយកពិធីជប់លៀង ដើម្បីទិញទឹកចិត្តមនុស្ស។

**គេឱ្យផឹកដោយប្រដាប់មាសដែលផ្សេងពីគ្នាទាំងអស់ ហើយ**

**មានស្រាទំពាំងបាយជូររបស់ហ្លួងជាបរិបូរ តាមសណ្ឋានស្តេច (នាងអេសធើរ១:៧)។**

ពិធីជប់លៀងនោះ សម្បូរទៅដោយគ្រឿងស្រវឹងគ្រប់ប្រភេទ។ ដូច្នេះ ពេលចេញពីជប់លៀងមកវិញ មនុស្សច្រើនណាស់ដែលពោលថា មិនដឹងជាអ្នកណាមកលើកផ្លូវ ដែលគាត់ធ្លាប់ដើរទៅណាបាត់ហើយ។

**តែគ្មានអ្នកណាបង្ខំឡើយ ដ្បិតស្តេចទ្រង់បានចេញច្បាប់ បង្គាប់ដល់ពួកភ្នាក់ងាររបស់ទ្រង់ ឱ្យបានធ្វើតាមចិត្តរបស់មនុស្សនីមួយៗ (នាងអេសធើរ១:៨)។**

គម្ពីរខាងលើសម្តែងថា ក្នុងពិធីជប់លៀងនេះ ឥតមានអ្នកណាបង្ខំអ្នកណាទេ គឺគ្រប់គ្នាអាចជ្រើសរើសទទួលទានគ្រឿងស្រវឹងក៏បាន មិនទទួលទានគ្រឿងស្រវឹងក៏បាន។ សម័យដើម សូម្បីស្តេចគ្រប់គ្រងដែលយើងយល់ថា មិនទាន់មានអរិយធម៌ គេអោយមនុស្សចេះជ្រើសរើស ថាតើគួរទទួលទានស្រា ឬមិនគួរ។ អ្នកធ្វើច្បាប់សម្រាប់ពិធីនោះ គេដឹកស្រាទាល់តែទន់ខ្លួន។ ប៉ុន្តែ អ្នកដែលមិនផឹកក៏ហីទៅ។ ដំណើរនេះយើងឃើញមានអនុវត្តក្នុងសង្គមយើងសព្វថ្ងៃនេះដែរ។ អាពាហ៍ពិពាហ៍នីមួយៗ បើមិនមានតាំងរូបស្រាទេ គេមិនសូវចង់ចូលរួមប៉ុន្មានឡើយ។ ដូច្នេះហើយ បានជានៅពេល

រៀបអាពាហ៍ពិពាហ៍ គេមិនអោយតម្លៃទៅលើការបង្កើតគ្រួសារថ្មីទេ គឺគេអោយតម្លៃទៅលើប្រភេទស្រា ដែលគេយកមកទទួលទាននៅពេលរៀបការវិញ។ ដូច្នេះហើយបានជាយើងឃើញគេចងរំយោលសញ្ញាដបស្រានៅក្នុងរោងការ ឬនៅតាមរោងជប់លៀង ស្ទើររកកន្លែងដកដង្ហើមមិនបាន។ បើអ្នកណាមិនផឹកស្រា គេមិនចូលចិត្តអោយអង្គុយតុជាមួយនឹងគេទេ។ ដូច្នេះ ដើម្បីអង្គុយចូលជាមួយគេបាន ចាំបាច់ត្រូវផឹកស្រា។ យើងតែងតែយល់ថា សព្វថ្ងៃយើងមានអរិយធម៌ប្រសើរជាងមនុស្សសម័យបុរាណ ប៉ុន្តែមនុស្សសម័យបុរាណគេមិនបង្ខំអោយអ្នកណាផឹកស្រាទេ សូម្បីនៅមុខព្រះមហាក្សត្រក៏ដោយ។

**ឯព្រះនាងវ៉ាសធី ជាអគ្គមហេសី ក៏ជប់លៀងដល់ពួកស្រីៗ នៅក្នុងព្រះរាជដំណាក់របស់ស្តេចអ័ហាស៊្វេរុសដែរ (នាងអេសធើរ ១:៩)។**

កំពុងតែព្រះបាទស្វ៊េរុសជប់លៀងដល់អ្នកដឹកនាំ ដែលសុទ្ធតែប្រុសៗ ព្រះនាងវ៉ាសធី ដែលជាអគ្គមហេសីរបស់ទ្រង់ បានធ្វើពិធីជប់លៀងដល់លោកជំទាវឯទៀតៗដែរ។ អ្នកដឹកនាំគ្រប់រូបនាំភរិយារបស់ខ្លួនមក ប៉ុន្តែ មិនអនុញ្ញាតអោយចូលរួមក្នុងពិធីជប់លៀងរបស់ពួកប្រុសៗទេ។ ទម្លាប់នេះ ជាទម្លាប់របស់មនុស្សនៅលោកខាងកើត។ លើសពីប្រពៃណី ពិធីជប់លៀងដ៏ធំនេះ ធ្វើឡើងសម្រាប់ទិញទឹកចិត្តអ្នក

នយោបាយ។ តាមគំនិតរបស់លោកខាងកើត គេមិនចង់អោយមានមនុស្សស្រីចូលរួមធ្វើនយោបាយទេ។ អ្នកដឹកនាំទាំង១២៧ប្រទេស កំពុងលក់គំនិតអោយព្រះបាទស៊ូរុសវិញដើម្បីធ្វើសង្គ្រាម។ ព្រះនាងវ៉ាសធីយល់ទឹកចិត្តប្តី បានជានាំពួកជំទាវៗធ្វើពិធីជប់លៀងនៅកន្លែងផ្សេង។

> **លុះដល់ថ្ងៃទី៧ ក្នុងកាលដែលស្តេចទ្រង់មានព្រះទ័យសប្បាយដោយស្រា នោះទ្រង់បង្គាប់ដល់មហ៊ូម៉ាន ប៊ីសថា ហាបូណា ប៊ីកថា អ័បាកថា សេថារ នឹងកើកាស ជាពួកក្រមវាំងទាំង៧នាក់ ជាអ្នកដែលបំរើនៅចំពោះស្តេចអ័ហាស៊ូរុស (នាងអេសធើរ ១:១០)។**

ខខាងលើសម្តែងថា ព្រះបាទស៊ូរុសស្រវឹងស្រា។ ស្តេចអង្គនេះទប់ខ្លួនមិនបានក៏បណ្តោយអោយស្រាចូលវាយគំនិតរបស់ទ្រង់ទៅ។ ស្តេចអង្គនេះជាអ្នកដាក់ច្បាប់ថា មនុស្សមិនចាំបាច់ផឹកស្រា ប៉ុន្តែ បើសិនជាផឹកសូមផឹកដូចងូតទៅចុះ។ កិរិយាប្រព្រឹត្តមិនគួរគប្បីរបស់ស្តេចស៊ូរុស ជាអ្នកដឹកនាំពិភពលោក ញ៉ាំងអោយយើងសួរសំណួរថា តើអ្នកដឹកនាំគួរផឹកស្រាអោយស្រវឹងទោរបែបនេះដែរឬទេ? ដំណើរនេះ យើងអាចធ្វើការសន្និដ្ឋានបានថា បើអ្នកដឹកនាំនគរទាំងមូលស្រវឹងស្រាទៅហើយ គាត់ក៏អាចស្រវឹងនឹងអំណាច ព្រមទាំងស្រវឹងនឹងអំពើអាក្រក់ផ្សេងៗជាយថាហេតុ។ ដូច្នេះ បើអ្នកដឹកនាំ

ស្រវឹងហើយ នគរមិនយូរមិនឆាប់នឹងត្រូវរលំរលាយជាប្រាកដ។

ខគម្ពីរខាងលើសម្តែងថា ព្រះបាទស៊ូរុសស្ថិតក្រោមឥទ្ធិពលគ្រឿងស្រវឹង។ ស្តេចអង្គនេះបានប្រព្រឹត្តការមួយ ដែលមិនត្រូវប្រព្រឹត្តជាដាច់ខាត។ ទ្រង់បង្គាប់អោយមេក្រមរាំងនាំព្រះនាងវ៉ាសធី មកបង្ហាញខ្លួននៅមុខពិធីជប់លៀងដ៏ធំរបស់ទ្រង់។ បើស្តេចអង្គនេះ មិនស្រវឹងស្រា ម្ល៉េះសមទ្រង់មិនប្រព្រឹត្តអំពើអបាយមុខនេះទេ។

**ឲ្យទៅនាំព្រះនាងវ៉ាសធី ជាអគ្គមហេសីមកនៅចំពោះទ្រង់ មានទាំងពាក់មកុដផង ដើម្បីនឹងសំដែងលំអព្រះរូបដល់បណ្តាជន នឹងដល់ពួកអ្នកជាប្រធានទាំងឡាយ ពីព្រោះព្រះនាងមានរូបឆោមល្អពេកណាស់ (នាងអេសធើរ១:១១)។**

ស្តេចស៊ូរុសចង់បញ្ជាក់ប្រាប់ដល់មេដឹកនាំនគរទាំង១២៧ថា លោកមានសមត្ថភាពអាចធ្វើសង្គ្រាមយ៉ាងធំនេះបាន ដោយបង្ហាញសម្បត្តិដ៏ពោរពាស ភាពរុងរឿងនគររបស់ទ្រង់។ ឥឡូវនេះ ក្រោមឥទ្ធិពលរបស់គ្រឿងស្រវឹង ស្តេចអង្គនេះ បានប្រព្រឹត្តការមួយដែលអ្នកធំមិនគួរធ្វើទាល់តែសោះ។ ស្តេចអង្គនេះចង់អោយគេយកព្រះនាងវ៉ាសធីមកបង្ហាញដល់បុរសៗរាប់ពាន់នាក់ថា នាងមានសម្រស់ស្អាតណាស់។ បើប្រសិនជាស្តេចអង្គនេះមិនស្រវឹង ស្តេចអង្គនេះមិនធ្វើយ៉ាងដូច្នោះឡើយ។ កិរិយាប្រព្រឹត្តរបស់ស្តេចអង្គនេះ ជាអំពើស្មោកគ្រោកយ៉ាងខ្លាំង។ ស្តេចអង្គនេះចង់អោយ

គេឃើញនាងវ៉ាសធីថា មានសម្រស់ស្អាត ម្យ៉ាងទៀតចង់អោយឃើញដុំពេជ្រ ដែលដាំនៅលើមកុដរបស់ព្រះនាងពាក់ផង។ ព្រះបាទស៊ែរុសចង់អួតពីសម្រស់របស់ប្រពន្ធផង និងអួតទ្រព្យសម្បត្តិដ៏មហាសាលរបស់ទ្រង់ផង។

> **តែព្រះនាងវ៉ាសធីមិនព្រមមកតាមបង្គាប់ស្ដេច ដោយសារពួកក្រមវាំងនោះទេ ហេតុនោះស្ដេចទ្រង់ក្រេវក្រោធជាខ្លាំង ហើយសេចក្ដីកំហឹងនោះក៏ឆួលឆេះឡើងក្នុងព្រះទ័យទ្រង់ (នាងអេសធើរ១:១២)។**

ព្រះគម្ពីរមិនបានសម្ដែងពីដំណើរនោះទេ ប៉ុន្តែ ខ្ញុំអាចពណ៌នាពាក្យរបស់ស្ដេចអង្គនោះយ៉ាងដូច្នេះថា "យើងមានជំនួនមួយសម្រាប់អ្នកចូលរួមពិធីជប់លៀងថ្ងៃនេះ។ អ្នករាល់គ្នានឹងភ្ញាក់ផ្អើលជាមិនខាន។ ខ្ញុំចង់អោយអស់លោកបានឃើញនឹងភ្នែកនូវសម្រស់របស់អគ្គមហេសីខ្ញុំ។ បន្តិចទៀត ព្រះនាងនឹងធ្វើដំណើរមកហើយ"។ ពិធីជប់លៀងចេះតែប្រព្រឹត្តទៅ ប្រមាណជាដប់ប្រាំនាទីក្រោយមក គេឃើញមានមេក្រមវាំងចូលមកឱនខ្សឹបព្រះការណ៍ព្រះមហាក្សត្រថា "ព្រះនាងមិនព្រមយាងមកទេ"។ នៅក្នុងសម័យនោះ ស្ត្រីក៏មានសិទ្ធិខ្លាំងណាស់ដែរ ដ្បិតព្រះនាងវ៉ាសធីអាចប្រឆាំងនឹងបញ្ជារបស់ស្ដេច ដោយប្រើសិទ្ធិរបស់នាងជាស្ត្រី។ ឧទាហរណ៍ បើស្ដេចយល់ព្រមជាមួយនឹងសិទ្ធិរបស់ស្ត្រី រួចហើយទ្រង់មានបន្ទូលទៅកាន់អ្នកចូលរួមក្នុងពិធីជប់លៀងថា

“អស់លោក ខ្ញុំសូមប្តូរកម្មវិធីបន្តិច ពីព្រោះអគ្គមហេសីរបស់ខ្ញុំមិនអាចមកបានដូចខ្ញុំគិតទេ”។ បើយ៉ាងដូច្នោះមែន ខ្ញុំជឿថាអ្នកដឹកនាំដទៃៗទៀតពិតជាវាយតម្លៃ ដល់ស្តេចស៊ូរុសថា “តើស្តេចនោះចង់គ្រប់គ្រងសកលលោកដូចម្តេចកើត បើគ្រប់គ្រងប្រពន្ធខ្លួនឯងមិនបានផង?”

ទោះបីខ្ញុំយល់ថា ព្រះនាងវ៉ាសធីមានសិទ្ធិនឹងបដិសេធមិនព្រមធ្វើតាមបញ្ជារបស់មហាក្សត្រ នាងគួរគិតសារជាថ្មីស្តីពីការសម្រេចចិត្ត ដែលមិនព្រមធ្វើតាមបញ្ជាព្រះករុណា។ នាងគួរគិតថា ការបដិសេធមិនព្រមធ្វើតាមបញ្ជារបស់ស្តេច អាចបង្អាប់បង្អោន ព្រមទាំងធ្វើអោយនាទីរបស់ប្តីនាងត្រូវធ្លាក់ចុះ។ ក្នុងកាលៈទេសៈបែបនេះ ព្រះនាងវ៉ាសធីគួរចូលមកបង្ហាញខ្លួន។ នាងត្រូវស្តាប់បញ្ជារបស់ប្តី។

**១៣ “ដូច្នេះ ស្តេចទ្រង់មានបន្ទូលសួរ ដល់ពួកអ្នកប្រាជ្ញ ដែលស្គាល់**
**សម័យប្រព្រឹត្ត ដ្បិតតាមទំលាប់របស់ស្តេច ទ្រង់តែងតែពិគ្រោះ**
**នឹងពួកអ្នកដែលចេះស្ទាត់ខាងច្បាប់ នឹងសេចក្តីវិនិច្ឆ័យ ១៤ “រីឯ**
**បន្ទាប់នឹងទ្រង់ មានកើសេណា សេថារ អ័ឌម៉ាថា តើស៊ីស**
**មេរេស ម៉ាសេណា នឹងមមូកាន ជានាយកនៃសាសន៍ពើស៊ី នឹង**
**សាសន៍មេឌី ទាំង៧នាក់ដែលធ្លាប់នៅចំពោះស្តេច ហើយជាអ្នក**
**លេខ១ក្នុងនគរ ១៥ “ទ្រង់សួរថា តាមច្បាប់ តើត្រូវធ្វើដូចម្តេចដល់**
**ព្រះនាងវ៉ាសធី ជាអគ្គមហេសី ដ្បិតព្រះនាងមិនបានធ្វើតាម**

**បង្គាប់យើង ដោយសារពួកក្រមរាំងទេ (នាងអេសធើរ១:១៣ -១៥)។**

ការមិនស្តាប់បង្គាប់របស់នាងវ៉ាសធី ធ្វើអោយខុទ្ទកាល័យរបស់ព្រះរាជាត្រូវធ្វើការប្រជុំជាបន្ទាន់។ ឈ្មោះបុរស៧ដែលរៀបរាប់នៅក្នុងខនេះ គឺជាអ្នកជំនិតរបស់ស្តេច ព្រមទាំងជាអ្នកផ្តល់ដំបូន្មានដល់ស្តេចគ្រប់ពេលគ្រប់វេលា។ រឿងនេះស្តាប់ទៅហាក់ដូចជាគួរអោយចង់សើច។ រឿងនោះជារឿងប្តីនិងប្រពន្ធសោះ ហេតុដូចម្តេចចាំបាច់អោយក្រុមប្រឹក្សារបស់ស្តេច ត្រូវសម្រេចរឿងនោះធ្វើអ្វី។ មែនហើយ រឿងនោះជារឿងគ្រួសារ ប៉ុន្តែ ជារាជ្យវង្ស។ ស្តេចបម្រុងនឹងធ្វើសង្គ្រាមមួយយ៉ាងធំ។ ព្រះនាងវ៉ាសធី ជាអគ្គមហេសីមិនព្រមស្តាប់បញ្ជាស្តេចទៅហើយ តើអោយស្តេចដទៃៗទៀតរបស់នគរទាំង១២៧ស្តាប់ស្តេចអង្គនោះដែរឬទេ? ដូច្នេះ បានជាទីប្រឹក្សាជាន់ខ្ពស់របស់ព្រះមហាក្សត្រចាំបាច់ត្រូវជួបជុំគ្នា ដើម្បីសម្រេចរឿងក្តីរបស់ព្រះនាងវ៉ាសធី។ ស្តេចសួរដល់ទីប្រឹក្សាជាន់ខ្ពស់ថា រឿងនេះត្រូវចាត់ចែងយ៉ាងដូចម្តេច? បើតាមសេចក្តីដែលរៀបរាប់នៅក្នុងអត្ថបទនេះ មើលទៅហាក់ដូចជាមិនដែលមានច្បាប់ណាទាក់ទងនឹងរឿងនេះ នៅក្នុងនគរទាំងមូលឡើយ។ ដូច្នេះ គេចាំបាច់ត្រូវធ្វើច្បាប់ថ្មី ដើម្បីដោះស្រាយបញ្ហាប្រពន្ធមិនស្តាប់បង្គាប់ប្តី។

**នោះមម្មកាន លោកទូលឆ្លើយនៅចំពោះស្តេច នឹងពួកនាយក**

**ទាំងប៉ុន្មានថា អគ្គមហេសី ព្រះនាងបានប្រព្រឹត្តខុស មិនមែនត្រឹមតែនឹងព្រះករុណាប៉ុណ្ណោះ គឺដល់ទាំងពួកអ្នកជាប្រធាន នឹងបណ្តាជនទាំងឡាយ ដែលនៅអស់ទាំងខេត្តរបស់ព្រះករុណាទៀតផង (នាងអេសធើរ១:១៦)។**

កន្លងមកទោះរឿងព្រេង ទោះរឿងពិត យើងតែងតែឮនិយាយជារឿយៗពីស្ត្រីដែលត្រួតប្តី។ រឿងនោះមានពិតមែន។ ក្នុងករណីព្រះនាងវ៉ាសធី នាងមិនមែនត្រួតស្តេចទេ គ្រាន់តែនាងប្រើសិទ្ធិសេរីភាពរបស់នាងប៉ុណ្ណោះ។ ឯច្បាប់ក៏មិនមែនបង្ខំនាងអោយចេះតែស្តាប់តាមប្តីរហូតដែរ។ ដូច្នេះ បានជាទីប្រឹក្សាជាន់ខ្ពស់របស់ស្តេចត្រូវសម្រេចរឿងក្តីនោះ។ នៅពេលប្រជុំរបស់ទីប្រឹក្សាជាន់ខ្ពស់ មានមនុស្សម្នាក់ឈ្មោះមមូកាន និយាយខ្លាំងៗជាងគេ។ បើតាមទំនង ខ្ញុំយល់ថាលោកមមូកានជាមនុស្សដែលប្រពន្ធត្រួតនៅក្នុងគ្រួសារ។ ហេតុដូចម្តេចបានជាយើងដឹងរឿងនោះ? ពីព្រោះ លោកខ្លាចថា បើស្តេចបណ្តោយអោយអគ្គមហេសីរបស់ទ្រង់ត្រួតស្តេចបាន ប្រពន្ធរបស់លោកក៏ត្រួតគាត់កាន់តែខ្លាំងដែរ។ លោកមមូកានជាមនុស្សចវាយចាញ់ប្រពន្ធ ហើយសួរថា តើឯងរាងចាលហើយឬនៅ?

សព្វថ្ងៃនេះ មនុស្សប្រុសជាច្រើននៅកន្លែងធ្វើការមានគេប្រើ មកដល់ផ្ទះបម្រើប្រពន្ធទៀត។ ដូច្នេះ គាត់មិនដឹងជារកទំនុកបែបណាដើម្បីបញ្ចេញកំហឹងរបស់ខ្លួនក៏ចេះតែនិយាយប៉ប៉ាច់ប៉ប៉ោច តែមិនសូវជាអ្នកសម្រេចការអ្វីបានជាច្រើនទេ។ នៅក្នុង

ក្រុមជំនុំ ក៏ដូច្នោះដែរ បើប៉ះមនុស្សដូចមម្មូកាននេះ គេនិយាយច្រើនណាស់ តែឥតយកដៃប៉ះការងារទេ។ លោកមម្មូកានជាមនុស្សបែបនោះ។

> **[១៧]ដ្បិតការដែលអគ្គមហេសីប្រព្រឹត្តនេះ នឹងឮទៅដល់ពួកស្រីៗទាំងអស់ បណ្តាលឱ្យគេមើលងាយដល់ប្តីរបស់ខ្លួនគ្រប់គ្នា ដោយដំណឹងនេះបានផ្សាយទៅថា ស្តេចអ័ហាស៊ូរុសបានបង្គាប់ឱ្យគេនាំព្រះនាង ជាអគ្គមហេសី មកចំពោះទ្រង់ តែព្រះនាងមិនព្រមស្តេចមកទេ [១៨]ហើយនៅថ្ងៃនេះ ពួកខុនណាងសាសន៍ពើស៊ី នឹងសាសន៍មេឌីទាំងប៉ុន្មាន ដែលឮនិយាយពីការអគ្គមហេសីបានធ្វើនេះ គេនឹងប្រកែកដល់ប្តីខ្លួន ជាពួកប្រធាននៃស្តេចដូច្នោះដែរ យ៉ាងនោះនឹងកើតមានសេចក្តីមើលងាយ នឹងសេចក្តីកំហឹងជាច្រើន (នាងអេសធើរ១:១៧-១៨)។**

លោកមម្មូកានជាសមាជិកក្រុមប្រឹក្សាជាន់ខ្ពស់ មានឋានន្តរស័ក្តិជាសម្តេចមួយរូបដែរ។ គាត់គិតពីហេតុការណ៍ដែលត្រូវកើតនៅផ្ទះរបស់លោក ពីព្រោះប្រពន្ធលោកត្រួតលោកជានិច្ច។ លោកមិនផ្តល់ដំបូន្មានដូចខាងលើទេ បើនៅផ្ទះរបស់លោកមិនមានរឿងនោះកើតឡើង។

ទាក់ទងនឹងបុរសខ្លាចប្រពន្ធ មានរឿងមួយដែលគេនិយាយតៗគ្នាមក។ បុរស

ម្នាក់ខ្លាចប្រពន្ធណាស់ ប្រពន្ធប្រាប់ទៅឆ្វេង គឺឆ្វេង ប្រពន្ធប្រាប់ទៅស្តាំ គឺស្តាំ ប្រពន្ធអោយចុះទឹកស្អុយ ចុះទឹកស្អុយ ប្រពន្ធអោយឡើងលើចុងឈើ ឡើងចុងឈើ ប្រពន្ធអោយស្រែក ស្រែក ប្រពន្ធអោយយំ យំ។ ថ្ងៃមួយគាត់មកដល់កន្លែងធ្វើការ គាត់បានប្រាប់មិត្តភក្តិថា "មានអី យប់មិញ ប្រពន្ធរបស់ខ្ញុំ លុតជង្គង់នៅមុខខ្ញុំ"។ ពួកអ្នកដែលគេស្គាល់គាត់បាននិយាយថា "មើល លោកចំណាប់ សូមលោកប្រាប់យើងមើលថា ប្រពន្ធឯងលុតជង្គង់យ៉ាងម៉េច?" គាត់បានប្រាប់ថា "ប្រពន្ធខ្ញុំ លុតជង្គង់មើលក្រោមគ្រែ រួចហើយនិយាយមកខ្ញុំថា របស់នេះនៅជ្រងោ ម៉េចក៏អាភ្លើឯងមើលមិនឃើញ!" លោកមមូកានស្នើររឿងនេះដល់ស្តេចថាៈ

> **បើសិនជាព្រះករុណាសព្វព្រះទ័យ នោះសូមទ្រង់ចេញព្រះរាជឱង្ការ ព្រមទាំងឱ្យគេកត់ទុកក្នុងច្បាប់របស់សាសន៍ពើស៊ី និងសាសន៍មេឌីផង ដើម្បីកុំឱ្យផ្លាស់បានឡើយ ហាមមិនឱ្យព្រះនាងចូលមកចំពោះព្រះករុណាទៀត ហើយសូមព្រះករុណាប្រគល់ដំណែងយសហ្លួងរបស់ព្រះនាង ដល់ស្ត្រីម្នាក់ទៀតដែលវិសេសជាង (នាងអេសធើរ១:១៩)។**

ខ្ញុំជឿថា លោកអ្នកពិតជាយល់ពីហេតុការណ៍ដែលកើតឡើងនៅក្នុងកណ្ឌព្រះគម្ពីរនាងអេសធើរ។ ហេតុការណ៍ទាំងនោះ គឺជាប្រពៃណីទំនៀមទម្លាប់របស់អ្នក

ដែលមិនស្គាល់ព្រះជាម្ចាស់។ រឿងនោះឥតទាក់ទងនឹងច្បាប់ទម្លាប់ក្រឹត្យវិន័យរបស់លោកម៉ូសេ ឬមួយជាទម្លាប់របស់គ្រីស្ទបរិស័ទក៏គ្មានដែរ។ ច្បាប់នោះជាច្បាប់ របស់សាសន៍ពើស៊ី ជាសាសន៍ដែលមិនស្គាល់ព្រះជាម្ចាស់។

> **[២០]ដូច្នេះ កាលណាព្រះរាជឱង្ការរបស់ស្តេចបានប្រកាសផ្សាយ**
> **ទៅគ្រប់ក្នុងនគរទ្រង់ (វីឯនគរទ្រង់នោះធំណាស់) នោះស្ត្រី**
> **ទាំងអស់នឹងគោរពប្រតិបត្តិដល់ប្តីខ្លួន ទោះទាំងធំទាំងតូចផង**
> **[២១]សេចក្តីនោះក៏គាប់ដល់ព្រះទ័យស្តេច នឹងចិត្តនៃពួកនាយកផង**
> **រួចស្តេចទ្រង់ក៏ធ្វើតាមពាក្យរបស់មម្មូកាន [២២]ទ្រង់ផ្ញើព្រះរាជសារ**
> **ទៅដល់អស់ទាំងខេត្តរបស់ស្តេច គឺដល់គ្រប់ទាំងខេត្តតាមអក្សរ**
> **ជាតិរបស់គេ ហើយទៅគ្រប់ទាំងសាសន៍ តាមភាសារបស់គេ**
> **បង្គាប់ថា មនុស្សប្រុសៗ ត្រូវធ្វើជាម្ចាស់លើផ្ទះរបស់ខ្លួន ហើយ**
> **សេចក្តីនោះក៏បានប្រកាសទូទៅ តាមភាសារបស់ជនគ្រប់ជាតិ**
> **(នាងអេសធើរ១:២០-២២)។**

សមាជិកក្រុមប្រឹក្សាជាន់ខ្ពស់ទាំងអស់យល់ស្របថា ចាប់ពីពេលនេះទៅព្រះនាងវ៉ាសធី មិនត្រូវមកជួបស្តេចទៀតទេ។ នាងឈប់មាននាទីជាអគ្គមហេសីទៀតហើយ។ បន្ថែមលើច្បាប់ទាំងនោះ គេបានធ្វើច្បាប់ថា ស្ត្រីគ្រប់រូបត្រូវលើកតម្កើងប្តី

របស់ខ្លួន។ បើតាមខ្ញុំយល់ ច្បាប់នោះក្លាយទៅជាប្រពៃណីនៅក្នុងប្រទេសមីឌុ និងប្រទេសពើស៊ី។ ឯច្បាប់ដែលបានដាក់ហើយនោះទៀតសោត មិនមានអ្នកណាមានសិទ្ធិប្តូរផ្លាស់ឡើយ សូម្បីស្តេចក៏គ្មានសិទ្ធិប្តូរបានដែរ។

ច្បាប់ដែលយើងឃើញដាក់ខាងលើនេះ សម្តែងពីភាពមិនប្រក្រតីនៃគំនិតរបស់ស្តេចស៊ូរុស។ ស្តេចអង្គនេះបានដឹកនាំកងទ័ពយ៉ាងធំមហិមា ដើម្បីទៅធ្វើចម្បាំង។ លោកជាមេទ័ពដែលបាននាំទ័ពរហូតទៅដល់ក្រុងធើម៉ូភីឡេ។ ម្យ៉ាងទៀតស្តេចអង្គនេះបានបញ្ជាសំពៅចំនួនបីរយគ្រឿង ដើម្បីចូលទៅព័ទ្ធប្រទេសក្រេក តែសំពៅទាំងនោះត្រូវគេបំផ្លាញខ្ទេចខ្ទីនៅកោះសាឡាមីស។ ស្តេចស៊ូរុសពិតជាបុរសដែលបណ្តោយអោយសេចក្តីក្រេវក្រោធគ្រប់គ្រងលើលោកមែន ដ្បិតពេលដែលលោកចុះពីសំពៅលោកហូតខ្សែក្រវាត់វាយទឹករលកសមុទ្រ ដោយខឹងថាមកពីរលកនេះឯង ដែលធ្វើអោយសំពៅរបស់លោកខូចខាតគ្មានសល់។ ការបរាជ័យក្នុងសង្គ្រាម ធ្វើអោយយើងវិនិច្ឆ័យបានថា ស្តេចស៊ូរុសមានខួរក្បាលមិនប្រក្រតី។ មែនហើយ អ្នកដឹកនាំដែលមានមហិច្ឆតាចង់គ្រប់គ្រងពិភពលោក សុទ្ធតែជាមនុស្សដែលមានខួរក្បាលមិនប្រក្រតី។ ព្រះរាជាជូលីសេសារ ស្តេចណាប៉ូឡេងអុង និងលោកអ៊ីត្លែជាដើម សុទ្ធតែជាមនុស្សដែលមានខួរក្បាលមិនប្រក្រតី។ ស្តេចនេប៊ូក្នេសារជាស្តេចដ៏ធំមួយអង្គ។ ស្តេចអង្គនេះបង្គាប់អោយគេសង់រូបសំណាករបស់ទ្រង់ធ្វើក្បាលពីមាសសុទ្ធ។ ប៉ុន្តែ ទោះជាស្តេចអង្គនេះ ជាបុរសជើងខ្លាំងយ៉ាងណាក៏ដោយ គេរកឃើញថា ស្តេចនេប៊ូក្នេសារកើតរោគសរសៃប្រសាទ។ នៅក្នុងព្រះគម្ពីរដានីយ៉ែល យើងឃើញមានរៀបរាប់ពីដំណើរ

ស្តេចអង្គនោះ ថាមានកិរិយាបែបនោះមែន។

សព្វថ្ងៃនេះ បុគ្គលណាក៏ដោយ បើចង់ធ្វើជាអ្នកដឹកនាំរបស់ពិភពលោក សូមអោយគ្រូពេទ្យឆ្លួតពិនិត្យជាមុនសិន។ ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ មានមនុស្សដែលមិនគ្រប់ទឹកឡើងធ្វើជាអ្នកដឹកនាំសកលលោកទាំងមូលក៏មានដែរ។ ករណីព្រះបាទស្វ៊ែរុសជាឧទាហរណ៍ស្រាប់។ ដោយសារគំនិតមិនគ្រប់ទឹក លោកបណ្តោយអោយគេយកមហេសីរបស់ទ្រង់ឆ្ងាយពីទ្រង់។ នៅពេលស្តេចអង្គនេះចង់ជួបជុំជាមួយមហេសីវិញទ្រង់មិនអាចបំពានលើច្បាប់ដែលទ្រង់បានធ្វើទេ។

# ជំពូក ២

*ចំណងជើង ការជ្រើសរើសបវរកញ្ញាធ្វើជាមហាក្សត្រី*

**ក្រោយការទាំងនោះមក កាលសេចក្តីក្រោធរបស់ស្តេចអ័ហាស៊្វេរុសបានស្ងប់ហើយ នោះទ្រង់ក៏នឹករឭកដល់ព្រះនាងវ៉ាសធី នឹងការដែលព្រះនាងបានធ្វើ ព្រមទាំងខសេចក្តី ដែលបានសំរេចដល់ព្រះនាងផង (នាងអេសធើរ២:១)។**

គម្ពីរនេះសម្តែងថា "ក្រោយការទាំងនោះមក..."។ តើក្រោយការអ្វី? ក្រោយពីធ្វើសង្គ្រាមជាមួយនឹងសាសន៍ក្រេកដោយទទួលបរាជ័យមក។ បន្ទាប់ពីបរាជ័យក្នុងសង្គ្រាម ស្តេចអង្គនេះបានត្រឡប់មកដល់នគរវិញ។ ស្តេចមានព្រះហឫទ័យព្រួយលំបាកយ៉ាងខ្លាំង ឯអគ្គមហេសីក៏ត្រូវគេបណ្តេញចេញពីព្រះរាជវាំងបាត់ទៅទៀត។ ដូច្នេះ ហើយធ្វើអោយស្តេចអង្គនេះ មានព្រះហឫទ័យសោកសង្រេងយ៉ាងខ្លាំង។

យើងចាំបាច់ត្រូវពិនិត្យមើលប្រវត្តិសាស្ត្រសកលោកបន្តិច ដើម្បីយល់ពីស្ថានភាពនេះ ពីព្រោះព្រះគម្ពីរមិនបានសម្តែងទេ។ ព្រះបាទស៊្វេរុសលើកទ័ពវាយសាសន៍ក្រេក។ ព្រះបាទស៊្វេរុសមានមនុស្សដូចស្រមោច ប៉ុន្តែ ឆន្ទៈធ្វើសង្គ្រាមចាញ់ទឹកចិត្តរបស់

ទាហានសាសន៍ក្រេកខ្លាំងណាស់។ សាសន៍ក្រេកយកចិត្តទុកដាក់នឹងសុខមាលភាពរបស់ទាហានខ្លួន ដូច្នេះទាហានមានទឹកចិត្តយ៉ាងខ្លាំង។ ទាហានសាសន៍ក្រេកម្នាក់មានកម្លាំងទឹកចិត្តស្មើនឹងទាហានស្តេចស៊ែរុសចំនួនមួយរយនាក់។ ដូច្នេះហើយ បានជាព្រះបាទស៊ែរុសមិនអាចយកជ័យជំនះក្នុងសង្គ្រាមនោះបាន ទោះបីលោកមានមនុស្សកុះករមានទ្រព្យសម្បត្តិយ៉ាងច្រើនក៏ដោយ។ បន្ទាប់ពីព្រះបាទស៊ែរុសចាញ់សង្គ្រាម អំណាចរបស់លោកខាងលិច បានចាប់ផ្តើមគ្របសង្កត់ទៅលើលោកខាងកើតជាបន្តបន្ទាប់។

ក្រោយពីព្រះបាទស៊ែរុសចាញ់សង្គ្រាម ស្តេចអង្គនេះមានចិត្តតែលតោល។ លោកគិតពីព្រះនាងវ៉ាសធី ដែលត្រូវគេបណ្តេញចេញពីព្រះរាជវាំង។ ដូច្នេះ មួយថ្ងៃៗស្តេចអង្គនេះ មានការអផ្សុកក្នុងព្រះហឫទ័យខ្លាំងណាស់។ ពួកបាវបម្រើរបស់ស្តេចបានដឹងរឿងនោះ បានជាគេត្រូវរៀបចំកម្មវិធីមួយដើម្បីរកអគ្គមហេសីថ្វាយស្តេច។

**២ នោះពួកមហាតលិកទាំងឡាយ ដែលបំរើស្តេចក៏ទូលទ្រង់ថា សូមទ្រង់ឲ្យគេទៅរកស្ត្រីក្រមុំ ដែលមានរូបស្រស់ល្អមកថ្វាយទ្រង់**
**៣ សូមព្រះករុណាចាត់ជំរើសឲ្យមានភ្នាក់ងារ នៅគ្រប់ខេត្តក្នុងនគរទ្រង់ ដើម្បីនឹងប្រមូលស្ត្រីក្រមុំ ដែលស្រស់ល្អទាំងប៉ុន្មាន មកឯស៊ូសាន ជាទីក្រុងហ្លួង ឲ្យនៅក្នុងមន្ទីរសំរាប់ពួកស្រីៗ ក្រោមអំណាចហេកាយ ជាក្រមវាំងរបស់ស្តេច ជាអ្នករក្សាពួកស្រីៗ**

**រួចឱ្យគេបើកគ្រឿង សំរាប់ជំរះខ្លួនដល់នាងទាំងនោះ (នាងអេសធើរ២:២-៣)។**

សមាជិកក្រុមប្រឹក្សាជាន់ខ្ពស់ បានធ្វើកម្មវិធីប្រលងរកបវរកញ្ញា ដើម្បីរកមហេសីថ្វាយស្តេច។ គេបានហៅនាងក្រមុំៗពីគ្រប់ទីកន្លែងក្នុងប្រទេសទាំង១២៧។ ខ្ញុំយល់ថា ក្រមុំៗទាំងនោះមានរាប់ពាន់នាក់ បានចូលមកប្រលងប្រជែងរើសបវរកញ្ញាពោលនោះ។

យើងស្លេះការសិក្សាគម្ពីរនាងអេសធើរត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"